Alameda County Health Care Services Agency
Public Health Department

Colleen Chawla, Director
Kimi Watkins-Tartt, Director
Nicholas Moss, MD, Interim Health Officer

សេចក្តីណែនាំអំពីការបើកឡើងវិញក្នុងអំឡុងវិបត្តិជំងឺកូវីដ-19 សម្រាប់អាជីវកម្មផ្សេងៗ ដែលបម្រើសេវាកម្មអ៊ុតសក់ និងកាត់សក់

ត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី07 ខែតុលា ឆ្នាំ2020

សម្គាល់៖ នៅថ្ងៃសុក្រ ទី 28 ខែសីហា ឆ្នាំ2020 រដ្ឋបានប្រកាសអំពីការផ្លាស់ប្តូរ ពីបញ្ជីត្រួតពិនិត្យរបស់រដ្ឋ មកអនុវត្តបួងមេសម្រាប់បើកឡើងវិញប្រកបដោយប្រសិទ្ធភាព ដែលកំណត់តាមពណ៌ មានបួនកម្រិតថ្នាក់។ ដើម្បីធ្វើបែបនេះបាន រដ្ឋបានផ្លាស់ប្តូរផែនការបើកឡើងវិញសម្រាប់អាជីវកម្ម និងសកម្មភាពមួយចំនួន ដោយបើកចំពោះអាជីវកម្ម និងសកម្មភាពមួយចំនួន ដែលធ្លាប់ត្រូវបានហាមឃាត់ និងដាក់ចេញនូវស្តង់ដារថ្មីសម្រាប់អាជីវកម្ម និងសកម្មភាពផ្សេងទៀត។ រដ្ឋក៏បានបញ្ជាក់ជាថ្មីផងដែរថា មន្ត្រីសុខាភិបាលក្នុងស្រុកមានសិទ្ធិអំណាចដាក់ចេញនូវការរិតត្បិត ដែលមានលក្ខណៈរឹតបន្តឹងខ្លាំងរដ្ឋ។

ដល់កម្រិតដែលអាចធ្វើទៅបាន ហាងអ៊ុតសក់ និងហាងកាត់សក់ ត្រូវបានលើកទឹកចិត្តឲ្យបម្រើសេវាកម្មរបស់ខ្លួននៅខាងក្រៅ។

គោលបំណងនៃឯកសារនេះ

ឯកសារនេះ ចែងអំពីសេចក្តីណែនាំសម្រាប់សេវាកម្មអ៊ុតសក់ និងកាត់សក់។ សេចក្តីណែនាំគឺដើម្បីជួយដល់បរិដ្ឋានមានសុវត្ថិភាព និងស្អាត សម្រាប់អ្នកផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់ និងអតិថិជន។ សូមទាក់ទងមក COVIDRecovery@acgov.org ប្រសិនបើអ្នកមានសំណួរ ឬត្រូវការជំនួយបច្ចេកទេស។ សម្រាប់ធនធានអាជីវកម្ម សូមចូលទៅ https://covid-19.acgov.org/recovery.page.

សម្គាល់៖ ផែនការបើកឡើងវិញរបស់ខោនធី Alameda គឺស្របនឹង បួងមេដើម្បីសេដ្ឋកិច្ចកាន់តែមានសុវត្ថិភាព ប៉ុន្តែនឹងមានលក្ខខណ្ឌមួយចំនួន ដែលខោនធី Alameda មានលក្ខណៈរឹតបន្តឹងខ្លាំងជាងលក្ខខណ្ឌរបស់រដ្ឋ។ លក្ខខណ្ឌមានលក្ខណៈរឹតបន្តឹងជាង ត្រូវយកជាគោល។

លក្ខខណ្ឌតម្រូវសម្រាប់អាជីវកម្ម

1. រៀបចំ និងអនុវត្ត ផែនការការពារជំងឺកូវីដ -19 សម្រាប់ទីតាំងជាក់លាក់ ផ្អែកលើសេចក្តីណែនាំតាមវិស័យរបស់រដ្ឋ និងមូលដ្ឋាន។
2. បណ្តុះបណ្តាលនិយោជិតអំពីការបង្ការជំងឺកូវីដ-19 ការពិនិត្យរករោគសញ្ញា ពាក់ម៉ាស់ និងសារៈសំខាន់នៃការរក្សាគម្លាតរូបកាយ និងការលាងសម្អាតដៃឲ្យបានញឹកញាប់។
3. អនុវត្តវិធានការពិនិត្យរករោគសញ្ញាចំពោះនិយោជិតទាំងអស់ និងមិនអនុញ្ញាតនិយោជិតណា ដែលបញ្ចេញរោគសញ្ញា ឲ្យមកធ្វើការឡើយ។ ឧបករណ៍ត្រួតពិនិត្យ មានក្រោមឧបករណ៍ និងធនធានសម្រាប់អាជីវកម្ម នៅ https://covid-19.acgov.org/recovery.page?
4. រៀបចំ និងអនុវត្តពិធីសារសម្អាត និងសម្លាប់មេរោគ នៅក្នុងផែនការពារសម្រាប់ទីតាំងជាក់លាក់។
5. បង្កើតគោលការណ៍ណែនាំស្តីពីគម្លាតរូបកាយ និងឯកសារនៅក្នុងផែនការការពារសម្រាប់ទីតាំងជាក់លាក់។
6. ធានាឲ្យបាននូវការគោរពអនុវត្តតាម បទបញ្ជាស្តីពីម៉ាស់របស់ខោនធី Alameda ដោយបុគ្គលទាំងអស់នៅទីតាំងអាជីវកម្មរបស់អ្នក (អតិថិជន និយោជិត អ្នកផ្គង់ផ្គង់ ។ល។)។ ទាំងអ្នកផ្តល់សេវាកម្មអ៊ុតសក់ និងទាំងអ្នកផ្តល់សេវាកម្មកាត់សក់ នឹងតម្រូវឲ្យពាក់ម៉ាស់ —រាប់ទាំងក្នុងអំឡុងបម្រើសេវាកម្មទាំងមូល—លើកលែងតែពួកគេត្រូវបានលើកលែងយ៉ាងជាក់លាក់ ចំពោះលក្ខខណ្ឌពាក់ម៉ាស់នេះ ក្នុងបទបញ្ជារបស់មន្ត្រីសុខាភិបាលលេខ 20-13 ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 15 ខែកក្កដា ឆ្នាំ2020 ឬពួកគេគោរពតាមលក្ខខណ្ឌជាក់លាក់ ដែលចែងខាងក្រោម។

7. គោរពអនុវត្តតាមសេចក្តីណែនាំ ដែលដាក់ចេញក្នុង ប្លង់មេរដ្ឋ California ដើម្បីសេដ្ឋកិច្ចកាន់តែមានសុវត្ថិភាព បទបញ្ជារបស់មន្ត្រីសុខាភិបាលមូលដ្ឋានទាំងអស់ និងបទប្បញ្ញត្តិជាធរមានរបស់រដ្ឋសហព័ន្ធ រដ្ឋ California និងមូលដ្ឋានទាំងអស់ ស្តីពីការឈប់សម្រាកឈឺមានប្រាក់ឈ្នួល សម្រាប់បុគ្គលណា ដែលមិនអាចធ្វើការងារបានប្រកបដោយសុវត្ថិភាព ដោយសារមូលហេតុទាក់ទងនឹងការរាលដាលជាសាកលនៃជំងឺកូវីដ-19។
8. "អ្នកផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់" សំដៅលើហាងអ៊ុតសក់ និងហាងកាត់សក់ ដែលធ្វើសកម្មភាពកាត់ ធ្វើ អ៊ុត កក់ សាប៊ូ រៀបចំ តុបតែង រមូល ប្រើសារធាតុគីមីរមូល ពន្លា ឬលាបព៍ណសក់ ឬប្រើម្ជុំជំនួយសក់។

លក្ខខណ្ឌសុខភាព និងសុវត្ថិភាព

ក្រៅពីការរៀបចំ ការបិទផ្សាយ និងអនុវត្ត ផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់ ដែលតម្រូវដោយបទបញ្ជានេះ ម្ចាស់ហាង ប្រតិបត្តិករ អ្នកគ្រប់គ្រង ឬអ្នកត្រួតពិនិត្យសេវាកម្មអ៊ុតសក់ និងកាត់សក់ ត្រូវតែចែងពីចំណុចនីមួយៗ ដូចខាងក្រោម នៅក្នុងផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់។

1. *ផ្នែកទី 1 – លក្ខខណ្ឌតម្រូវចំពោះសេវាកម្មអ៊ុតសក់ និងកាត់សក់៖*

   1.1. សកម្មភាពដែលតម្រូវឲ្យដោះម៉ាស់របស់អតិថិជន មានហានិភ័យឆ្លងជំងឺកូវីដ-19 កាន់តែខ្ពស់ ហើយអ្នកផ្តល់សេវាអ៊ុតសក់ និងកាត់សក់ ត្រូវបានហាមឃាត់មិនឱ្យផ្តល់សេវាកម្ម ដែលតម្រូវឱ្យដោះម៉ាស់របស់អតិថិជនទេ។ ផ្អែកលើកម្រិតឆ្លងជំងឺកូវីដ-19 នៅក្នុងសហគមន៍ សេវាកម្មបែបនេះ ដែលតម្រូវឱ្យដោះម៉ាស់របស់អតិថិជន អាចត្រូវបានអនុញ្ញាតនាពេលអនាគត។

   1.1.1. ការបកវោមមុខដែលតម្រូវឱ្យដោះរបាំងមុខ និងការធ្វើមុខផ្សេងទៀត ត្រូវបានហាមឃាត់ នៅពេលនេះ។

   1.2. តម្រូវឲ្យអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ពាក់ម៉ាស់ ដូចចែងនៅក្នុងបទបញ្ជាសុខាភិបាលលេខ 20-13 ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 15 ខែកក្កដា ឆ្នាំ2020 និងវិសោធនកម្មនាអនាគតលើបទបញ្ជានោះ ("បទបញ្ជាស្តីពីម៉ាស់")។ អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវពាក់ម៉ាស់ និងរបាំងមុខគ្រប់ពេលទាំងអស់ នៅពេលពួកគេកំពុងបម្រើសេវាកម្មដល់អតិថិជន។

   1.2.1. តាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ California និយោជកត្រូវផ្តល់ម៉ាស់ជូនបុគ្គលិក ឬបង្ខិលសងបុគ្គលិកវិញ ចំពោះចំណាយសមរម្យលើការទិញម៉ាស់។

   1.2.2. តាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ California និយោជកត្រូវតែផ្តល់ និងធានាថា បុគ្គលិកប្រើប្រាស់គ្រឿងបរិក្ខាការពារដែលតម្រូវទាំងអស់ រាប់ទាំង ស្រោមដៃ និងរបាំងមុខ។

   1.3. លើកទឹកចិត្តឲ្យអតិថិជនយកម៉ាស់ផ្ទាល់ខ្លួនមកជាមួយ និងប្រើប្រាស់ម៉ាស់ផ្ទាល់ខ្លួន។ អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវផ្តល់ម៉ាស់ជូនអតិថិជន ប្រសិនបើអតិថិជនគ្មានម៉ាស់ទេ ឬត្រូវបដិសេធមិនបម្រើសេវាកម្មជូនអតិថិជនទាំងឡាយ ដែលមកដល់គ្មានម៉ាស់ ឬបដិសេធ មិនពាក់ម៉ាស់ និងដែលមិនត្រូវបានលើកលែង ចំពោះការពាក់ម៉ាស់ នៅក្នុងបទបញ្ជាស្តីពីម៉ាស់។ បទបញ្ជាស្តីពីម៉ាស់របស់មន្ត្រីសុខាភិបាល តម្រូវឲ្យមានឯកសារលើកលែងជាលាយលក្ខណ៍អក្សរ ចេញដោយអ្នកជំនាញវេជ្ជសាស្ត្រ ដោយផ្អែកលើស្ថានភាពសុខភាព បញ្ហាសុខភាព ឬពិការភាព។

   1.3.1. អតិថិជន ដែលត្រូវបានលើកលែងនៅក្នុងបទបញ្ជាស្តីពីម៉ាស់ គួរត្រូវបានហាមឃាត់ មិនឱ្យនិយាយស្តី ព្រោះការនិយាយស្តីបណ្តាលឲ្យអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក មានហានិភ័យខ្ពស់ឆ្លងមេរោគជំងឺកូវីដ-19 ប្រសិនបើអតិថិជនបានឆ្លងជំងកូវីដ-19 នេះរួចហើយ។

   1.3.2. ទុកដាក់ក្រដាសជូតមុខដែលប្រើរួចចោល សម្រាប់អតិថិជនប្រើប្រាស់ ករណីអតិថិជនត្រូវកណ្តាស់

ឬក្អក ខណៈពេលមិនពាក់ម៉ាស់។ អតិថិជនត្រូវបោះចោលក្រដាសនោះដោយខ្លួនឯង ដូច្នេះ អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក មិនត្រូវចាត់ចែងលើក្រដាសកខ្វក់នោះឡើយ។

1.4. អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវបម្រើសេវាកម្មជូនអតិថិជន តាមការណាត់តែប៉ុណ្ណោះ ហើយមិនត្រូវផ្តល់សេវាកម្មជូនអតិថិជនដែលដើរចូលហាងនៅពេលនេះឡើយ។ អ្នកផ្តល់សេវាកម្ម ត្រូវរៀបចំការណាត់ ដើម្បីកាត់បន្ថយការកកស្ទះ និងធានាឲ្យបាននូវពេលវេលាគ្រប់គ្រាន់ សម្រាប់ការសម្អាត និងសម្លាប់មេរោគឲ្យបានសមរម្ម បន្ទាប់ពីបម្រើសេវាកម្មជូនអតិថិជនម្នាក់ៗ។

1.4.1. ហាមឃាត់អតិថិជន មិនឱ្យនាំមនុស្សមកបន្ថែម នៅពេលណាត់ លើកលែងតែករណីលើកលែងដូចខាងក្រោម៖ (1) ប្រសិនបើអតិថិជនដែលទទួលសេវាកម្ម គឺជាអនីតិជន ពួកគេអាចនាំអាណាព្យាបាលជាមនុស្សពេញវ័យ (2) ប្រសិនបើអតិថិជន ដែលទទួលសេវាកម្ម គឺជាជនពិការ ពួកគេអាចនាំអ្នកផ្តល់សេវាថែទាំជាមនុស្សពេញវ័យ និង (3) អតិថិជនពេញវ័យ អាចនាំកូនតូចៗរបស់ខ្លួន ប្រសិនបើពួកគេគ្មានជម្រើសថែទាំកុមារផ្សេងទៀតទេ។ អ្នកណាដែលចូលក្នុងគ្រឹះស្ថាន ត្រូវពិនិត្យរករោគសញ្ញាជំងឺកូវីដ-19 និងត្រូវរាប់បញ្ចូល នៅពេលគេសម្រេចថាតើទីតាំងមានចំនួនមនុស្សដល់កម្រិតរបស់ទីតាំង ឬយ៉ាងណា។

1.4.2. ហាមឃាត់អតិថិជន កុំឲ្យប្រមូលផ្តុំគ្នានៅកន្លែងទទួលភ្ញៀវ ឬកន្លែងផ្សេងទៀតក្នុងគ្រឹះស្ថាន។ ស្នើអតិថិជនរង់ចាំខាងក្រៅ ដោយពាក់ម៉ាស ឬក្នុងរថយន្តរបស់ខ្លួន មុនពេលណាត់ ។ នៅទីតាំងកាន់តែជំ កន្លែងទទួលភ្ញៀវគួរមានអតិថិជនម្តងម្នាក់ ឬកែប្រែកន្លែងទទួលភ្ញៀវ ដើម្បីអាចរក្សាគម្លាតរូបកាយយ៉ាងតិចប្រាំមួយហ្វីត ដែលរួមបញ្ចូល ការយកកៅអី ឬសាឡុងចេញ ឬការដាក់របាំងលើកៅអី ឬសាឡុង។

1.5. អ្នកផ្តល់សេវាកម្ម ត្រូវតែទូរស័ព្ទទៅអតិថិជន មុនពេលណាត់ ដើម្បី៖

1.5.1. បញ្ជាក់ថា អតិថិជនមិនមានរោគសញ្ញា ឬធ្វើតេស្តវិជ្ជមានជំងឺកូវីដ-19 ទេ ក្នុងអំឡុងរយៈពេល 14 ថ្ងៃ មុន ហើយមិនបានប៉ះពាល់អ្នកដែលមានរោគសញ្ញា ឬអ្នកដែលធ្វើតេស្តវិជ្ជមានជំងឺកូវីដ-19 នៅក្នុងរយៈពេល 14 ថ្ងៃមុនទេ។

1.5.2. ប្រាប់អតិថិជនឲ្យមកតែម្នាក់ឯង (លើកលេងតែឪពុក/ម្តាយ ឬអាណាព្យាបាល ត្រូវអមដំណើរអនីតិជន ឬអ្នកថែទាំ ដែលត្រូវអមដំណើរអតិថិជនដែលជាជនពិការ។ និង

1.5.3. ប្រាប់ពួកគេ កុំឲ្យមកដល់ហាងមុនពេលណាត់ លើសពី 5 នាទី។

1.6. អតិថិជនដែលកំពុងឈឺ ឬបានបញ្ចេញរោគសញ្ញាជំងឺកូវីដ-19 ក្នុងរយៈពេល 24 ម៉ោង មុនការណាត់របស់ខ្លួន ត្រូវលុបចោល ឬកំណត់ពេលណាត់ឡើងវិញ។ អតិថិជន ដែលមានជំងឺកូវីដ-19 មិនអាចមកតាមការណាត់ទេ រហូតទាល់តែពួកគេលែងឆ្លងជំងឺ ដែលជាធម្មតា 10 ថ្ងៃ បន្ទាប់ពីចេញរោគសញ្ញា 10 ថ្ងៃក្រោយការធ្វើតេស្តវិជ្ជមានលើកដំបូង ឬប្រសិនបើគ្មានរោគសញ្ញា។ ការធ្វើតេស្តម្តងទៀត ដើម្បីបង្ហាញពីការជាសះស្បើយ មិនមែនជាអនុសាសន៍ទេ។

1.7. ពិនិត្យអតិថិជនទាំងអស់ នៅពេលមកដល់។ ត្រូវបដិសេធ មិនបម្រើសេវាកម្មជូនអតិថិជនដែលមិនឆ្លងផុតការពិនិត្យ ហើយការណាត់របស់ពួកគេ គួរកំណត់ពេលថ្មី ឬគួរលុបចោល។ សូមចូលទៅ ទីនេះ ដើម្បីបានសេចក្តីណែនាំស្តីពីការពិនិត្យសម្រាប់និយោជក។

1.8. តម្រូវឲ្យអតិថិជនលាងសម្អាតដៃយ៉ាងតិច 20 វិនាទី ឬប្រើដែលលាងដៃ មុនពេលបម្រើសេវាកម្ម។

2. ផ្នែកទី 2 – លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់គ្រឹះស្ថាន ដែលផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់៖

2.1. ប្រសិនបើគ្រឹះស្ថានសេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចកទាំងមូល ឬផ្នែកណាមួយ ទំនេរ ឬគ្មានដំណើរការ ក្នុង

អំឡុងបទបញ្ហា ស្ថាក់នៅក្នុងទីជម្រក ដូចនេះ អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវធានាថា បំពង់ទឹកដំណើរការ ហើយបំពង់ផ្គត់ផ្គង់ទឹកត្រូវបានបង្ហូរចោល មុនពេលប្រើប្រាស់។ តំណភ្ជាប់ខាងក្រោម ចែងពីសេចក្តីណែនាំសម្រាប់ការបង្ហូរទឹក និងរៀបចំប្រព័ន្ធទឹកនៅ៖ https://www.ebmud.com/water/about-your-water/water-quality/returning-service-after-prolonged-outage/.

2.2. ពេលដែលអាចធ្វើទៅបាន ត្រូវហាមឃាត់អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក កុំឲ្យប្រើគ្រឿងបរិក្ខាររួមគ្នា ដូចជា ទូរស័ព្ទ ថេប្លេត ឬកុំព្យូទ័រ។ គ្រឿងសង្ហារិម ឧបករណ៍ ឬគ្រឿងបរិក្ខាណា ដែលត្រូវប្រើដោយបុគ្គលលើសពីម្នាក់ ត្រូវសម្លាប់មេរោគ បន្ទាប់ពីបានប្រើរួច តាមរបៀបស្របតាមលក្ខខណ្ឌតម្រូវ ដែលចែងក្នុងផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់។ ប្រសិនបើអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវប្រើកន្លែងធ្វើការរួមគ្នា ដូចជា ការជួលវេន ដូច្នេះ ទីតាំងនោះត្រូវសម្លាប់មេរោគ តាមរបៀបស្របតាមលក្ខខណ្ឌតម្រូវ ដែលចែងក្នុងផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់ បន្ទាប់ពីការប្រើប្រាស់ម្តងៗ។

2.3. រៀបចំផែនការ និងអនុវត្តផែនការពិនិត្យខ្លួនឯងរករោគសញ្ញាជំងឺកូវីដ-19 ប្រចាំថ្ងៃ ចំពោះអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចកទាំងអស់ ដែលតម្រូវនៅក្នុងផែនការ ការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់។

2.4. យកផលិតផលគំរូចេញ និងហាមឃាត់ការប្រើផលិតផលគំរូ។

2.5. កុំផ្តល់អាហារ និងភេសជ្ជៈជូនអតិថិជន។

2.6. យករបស់របរចល័តចេញពីផ្ទៃដែលមិនអាចសម្អាតបានសមរម្យ ដូចជា ខ្នើយទ្រាប់ ភួយ ឬ ទស្សនាវដ្តី។ ពិចារណាគ្រប ឬយកចេញនូវវត្ថុផ្សេងទៀតដែលពិបាកសម្អាត ដែលអតិថិជនប៉ះពាល់។

2.7. រៀបចំកៅអីរឹងមិនជ្រាប ឬកន្ត្រក ឬថង់ប្លាស្ទិក ឬថង់ក្រដាសធំៗ ឬធ្នើរញ្ជូរអាវធំ/មួកសម្រាប់អតិថិជនដាក់សម្លៀកបំពាក់ និងរបស់របរផ្សេងទៀត។ សម្លាប់មេរោគលើកៅអី កន្ត្រកប្លាស្ទិក និងធ្នើរញ្ជូរអាវធំ/មួក បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។ ពេលញ្ជូររបស់របរ ត្រូវធានាថា របស់នោះមិនប៉ះពាល់នឹងរបស់របររបស់អតិថិជនផ្សេងទៀតឡើយ។

2.8. អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវតែពាក់ស្រោមដៃដែលប្រើរួចចោល នៅពេលតម្រូវដើម្បីបម្រើសេវាកម្មណាមួយ (ឧទាហរណ៍ សេវាកម្មធ្វើសក់ប្រើសារធាតុគីមី) នៅពេលសម្អាត និងសម្លាប់មេរោគ នៅពេលយកក្រណាត់ និងកន្សែងដែលបានប្រើរួចចេញ និងនៅពេលចាត់ចែងលើវត្ថុដែលកង្វក់ ដោយសារអង្គធាតុរាវនៃរាងកាយ។ ការពាក់ស្រោមដៃ មិនជំនួសការលាងសម្អាតដៃ ឲ្យបានទៀងទាត់ឡើយ។ ត្រូវប្រើស្រោមដៃម្តងជាមួយអតិថិជនម្នាក់។ ស្រោមដៃ គួរបោះចោលប្រកបដោយសុវត្ថិភាព បន្ទាប់ពីប្រើរួច ហើយអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវលាងសម្អាតដៃឱ្យបានហ្មត់ចត់ បន្ទាប់ពីដោះ និងចោលស្រោមដៃ។ ម្យ៉ាងទៀត អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវលាងសម្អាតដៃ បន្ទាប់បម្រើអតិថិជនរួច និងនៅមុនពេលពាក់ស្រោមដៃថ្មី។

2.9. សេវាកម្មអ៊ុតសក់ និងកាត់សក់ ត្រូវតែធ្វើឡើង ក្នុងគម្លាតយ៉ាងតិចប្រាំមួយហ្វីតឆ្ងាយពីអ្នកផ្តល់សេវាកម្ម អ៊ុតសក់ និងកាត់សក់ និងអតិថិជនផ្សេងទៀត។

2.10. បញ្ឈប់ការប្រើប្រាស់ឧបករណ៍ម្ហូបអាហារ និងភេសជ្ជៈរួមគ្នា នៅក្នុងបន្ទប់សម្រាក (រួមទាំងម៉ាស៊ីនឆុងកាហ្វេរួមគ្នាផងដែរ)។

2.11. រៀបចំផែនការ និងអនុវត្តលក្ខខណ្ឌសម្អាត និងសម្លាប់មេរោគ ដែលមានកម្រិតលើសពីលក្ខខណ្ឌ និងស្តង់ដារវិជ្ជាជីវៈធម្មតា ក្នុងនោះ រួមបញ្ចូល៖

2.11.1. ជ្រាប់អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចកទាំងអស់ ឲ្យលាងសម្អាតដៃឱ្យបានញឹកញាប់ ដោយប្រើសាប៊ូ និងទឹក យ៉ាងតិច 20 វិនាទី ឬប្រើប្រាស់ដែលលាងដៃ (ដែលបានផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក) រួមមាន នៅមុន និងក្រោយពេលប៉ះពាល់លើផ្ទៃប៉ះពាល់

ច្រើនគ្នា ដូចជា កន្លែងគិតលុយ ឬឧបករណ៍ គ្រឿងបរិក្ខា ឬសម្ភារដែលប្រើរួមគ្នា នៅពេលប្តូរ ឬតម្រង់ម៉ាស់របស់ខ្លួន ឬនៅពេលមានឱកាសឆ្លងមេរោគ។

2.11.2. សម្លាប់មេរោគនៅកន្លែងបម្រើសេវាកម្ម រទេះរុញ ប្រអប់ថត កញ្ចក់កាន់ដៃ ឧបករណ៍ដែលបានប្រើលើអតិថិជន កន្សែងក្តៅ និងផ្ទៃផ្សេងទៀត បន្ទាប់ពីបម្រើអតិថិជនរួច។

2.11.3. វត្ថុប្រើតែម្តង ដូចជា កក្រមួន ដុំ/ក្បាល់សំឡី ក្រដាសរុំក និងវត្ថុផ្សេងៗ ត្រូវតែប្រើម្តងរួចបោះចោលភ្លាមៗក្នុងធុងបិទជិត។

2.11.4. ឧបករណ៍ទាំងអស់នៅកន្លែងបម្រើសេវាកម្មត្រូវសម្លាប់មេរោគឲ្យបានត្រឹមត្រូវ បន្ទាប់ពីបម្រើអតិថិជនម្នាក់ៗរួច តាមលក្ខខណ្ឌដូចខាងក្រោម៖

2.11.4.1. សម្អាត និងសម្លាប់មេរោគនៅលើឧបករណ៍ដែលមិនជ្រាបទឹក និងខ្សាច់ និងមិនប្រើអគ្គិសនីផ្សេងទៀតទាំងអស់ ដោយយកកំទេចមើលឃើញទាំងអស់ចេញ លាងជាមួយសាប៊ូ និងទឹក សម្ងួតឧបករណ៍ ហើយដាក់ត្រាំក្នុងទឹកសម្លាប់មេរោគ ដែលចុះបញ្ជី EPA។ សម្អាត និងសម្លាប់មេរោគនៅលើកន្ត្រៃកាត់សក់ ក្រាស់សិត និងច្រាស់ ដោយយកកំទេចមើលឃើញទាំងអស់ចេញ លាងជាមួយសាប៊ូ និងទឹក ហើយជូត ឬបាញ់ ទឹក ឬក្រដាសសម្លាប់មេរោគដែលចុះបញ្ជី EPA ដែលបង្ហាញពីប្រសិទ្ធភាពសម្លាប់បាក់តេរី ផ្សិត និងមេរោគ និងត្រូវបានអនុម័ត សម្រាប់មេរោគកូរ៉ូណា។ គួរបាញ់ ឬដាក់ត្រាំឧបករណ៍ក្នុងរយៈពេល ដែលតម្រូវដោយអ្នកផលិតទឹកសម្លាប់មេរោគ។

2.11.4.2. សម្អាត និងសម្លាប់មេរោគលើឧបករណ៍អគ្គិសនីទាំងអស់ ដូចជា ម៉ាស៊ីនកៀបសក់ អំពូល LED និងឧបករណ៍កែសម្ផស្ស ដោយយកកំទេចមើលឃើញទាំងអស់ចេញ និងសម្លាប់មេរោគ ដោយបាញ់ ឬជូតនឹងទឹក ឬក្រដាសសម្លាប់មេរោគដែលចុះបញ្ជី EPA ដែលបង្ហាញពីប្រសិទ្ធភាពសម្លាប់បាក់តេរី ផ្សិត និងមេរោគ និងត្រូវបានអនុម័តសម្រាប់មេរោគកូរ៉ូណា។ បន្ទាប់មក ប្រើទឹក ឬក្រដាសសម្លាប់មេរោគ ដែលចុះបញ្ជី EPA សម្រាប់រយៈពេលបាញ់ ឬជូត ដែលបានចែងក្នុងសេចក្តីណែនាំរបស់អ្នកផលិត។ ត្រូវប្រុងប្រយ័ត្ន ពេលបាញ់ទឹកសម្លាប់មេរោគ និងត្រូវដកឧបករណ៍របស់អ្នកចេញពីព្រើភ្លើង ហើយកុំបាញ់ចូលម៉ូទ័រ។ ត្រូវពិចារណាប្រើគម្របអាចជូតបានសម្រាប់ឧបករណ៍អេឡិចត្រូនិច។ ប្រសិនបើមិនមានការណែនាំពីអ្នកផលិតទេ ត្រូវពិចារណារប្រើក្រដាសជូត ឬទឹកបាញ់មានអាល់កុលយ៉ាងហោចណាស់ 60 ភាគរយ ដើម្បីសម្លាប់មេរោគលើអេក្រង់ថាច់។ សម្ងួតផ្ទៃឲ្យហ្មត់ចត់ ដើម្បីចៀសវាងកុំឲ្យដក់អង្គធាតុរាវ។

2.11.5. សម្អាត និងសម្លាប់មេរោគលើដៃ ទុយោទឹក ក្បាលបាញ់ទឹក និងឧបករណ៍ផ្សេងទៀត បន្ទាប់ពីបម្រើអតិថិជនរួច។ កៅអី កន្លែងកើយក្បាល ចានសាប៊ូ និងរបស់របរផ្សេងៗទៀត គួរសម្អាត និងសម្លាប់មេរោគឱ្យបានហ្មត់ចត់ បន្ទាប់ពីការប្រើប្រាស់។ ត្រូវពិចារណាបន្ថែមក្រដាសគ្រប ឬសន្លឹកក្រដាសដែលត្រូវបោះចោល បន្ទាប់ពីការប្រើប្រាស់ម្តងៗ។

2.11.6. ក្រណាត់កខ្វក់ទាំងអស់ រួមមានកន្សែង ក្រណាត់ ភួយ អាវក្រៅ និងក្រណាត់គ្របគ្នានដៃ ដែលអាចប្រើបានឡើងវិញ គួរដាក់ក្នុងធុងបិទជិត និងមិនត្រូវប្រើម្តងទៀតទេ រហូតដល់ទាល់តែបានបោកគក់បានត្រឹមត្រូវ ដោយសេវាកម្មបោកគក់ ឬដំណើរការបោកគក់ ដែលរួមបញ្ចូលការដាក់ត្រាំក្នុងទឹកសីតុណ្ហភាពយ៉ាងតិច 160 Fahrenheit យ៉ាងតិច 25 នាទី។ ត្រូវរក្សាក្រណាត់ស្អាតនៅកន្លែងស្អាតបិទជិត។ ត្រូវធានាថា អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ដែលចាត់ចែងលើក្រណាត់កខ្វក់ ឬការបោកគក់ ត្រូវពាក់ស្រោមដៃ និងម៉ាស់។

3. *ផ្នែកទី 2 – លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់គ្រឹះស្ថាន ដែលផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់៖*

3.1. ធ្វើការកែតម្រូវដែលចាំបាច់នៅលើប្លង់គ្រឹះស្ថាន ដើម្បីឲ្យមានគម្លាតរូបកាយសមរម្យ។ ឧទាហរណ៍ កៅអី និងកន្លែងបម្រើសេវាកម្ម ត្រូវតែរៀបចំយ៉ាងណា ដើម្បីធានាគម្លាតយ៉ាងតិចជ្រាំមួយហ្វីតរវាងអតិថិជន។ គ្រឹះស្ថានគួរពិចារណាប្រើប្រាស់ខណ្ឌបែងបន្ថែម ឬរបាំងមិនជ្រាបទឹកផ្សេងទៀត នៅពេលសមរម្យ។

3.2. ប្រសិនបើគ្រឹះស្ថានសេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចកទាំងមូល ឬផ្នែកណាមួយ ទំនេរ ឬគ្មានដំណើរការ ក្នុងអំឡុងបទបញ្ហា ស្ងាត់នៅក្នុងទីជម្រក ដូចនេះ អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវធានាថា បំពង់ទឹកដំណើរការ ហើយបំពង់ផ្គត់ផ្គង់ទឹកត្រូវបានបង្ហូរចោល មុនពេលប្រើប្រាស់។ តំណភ្ជាប់ខាងក្រោម ចែងពីសេចក្តីណែនាំសម្រាប់ការបង្ហូរទឹក និងរៀបចំប្រព័ន្ធទឹកនៅ៖ https://www.ebmud.com/water/about-your-water/water-quality/returning-service-after-prolonged-outage/.

3.3. ធ្វើការកែលម្អដែលចាំបាច់លើប្រព័ន្ធខ្យល់ចេញចូលក្នុងគ្រឹះស្ថាន ដែលរួមបញ្ចូល៖

3.3.1. ធានាថា ប្រព័ន្ធ HVAC និងប្រព័ន្ធប្តូរខ្យល់ ត្រូវបានជួសជុល និងដំណើរការបានត្រឹមត្រូវ។ ធានាថា តម្រងខ្យល់ទាំងអស់ ដំណើរការបានលទ្ធផលល្អប្រសើរបំផុត ហើយត្រូវបានប្តូរថ្មីទាន់ពេលវេលា អនុលោមតាមអនុសាសន៍របស់អ្នកផលិត។

3.3.2. គ្រឹះស្ថានសេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវបង្កើនភាគរយខ្យល់ពីខាងក្រៅ តាមប្រព័ន្ធ HVAC បិទដំណើរការនូវប្រព័ន្ធគ្រប់គ្រងខ្យល់តាមតម្រូវការ ដែលកាត់បន្ថយបរិមាណខ្យល់ផ្អែកលើសីតុណ្ហភាព ឬចំនួនអ្នកកាន់កាប់ និងបង្កើនខ្យល់ធម្មជាតិ ដោយបើកបង្អួច និងទ្វារ នៅពេលអាចធ្វើបាន ដោយសារស្ថានភាពបរិស្ថាន និងអគារ។

3.3.3. ពិចារណាប្រើប្រាស់ម៉ាស៊ីនចល័យសម្អាតខ្យល់ដែលមានប្រសិទ្ធភាពខ្ពស់ (HEPA) អាប់ក្រេតតម្រងខ្យល់ក្នុងអគារឲ្យមានប្រសិទ្ធភាពខ្ពស់ ដំណើរការប្រព័ន្ធខ្យល់ក្នុងអគារ ពេលគ្មានមនុស្ស ដើម្បីបង្កើនខ្យល់ចេញចូលជាអតិបរមា និងធ្វើការកែសម្រួលផ្សេងទៀត ដើម្បីបង្កើនបរិមាណខ្យល់បរិសុទ្ធពីខាងក្រៅ និងចរន្តខ្យល់ នៅកន្លែងធ្វើការទាំងអស់។

3.4. រៀបចំផែនការ និងអនុវត្តនូវលក្ខខណ្ឌតម្រូវស្តីពីការសម្អាត និងសម្លាប់មេរោគ ដែលរួមបញ្ចូល៖

3.4.1. ណែនាំអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចកថា ពួកគេត្រូវទទួលខុសត្រូវសម្អាតកន្លែងធ្វើការរបស់ខ្លួនឱ្យបានស្អាត និងមានអនាម័យ។ អ្នកផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់ម្នាក់ៗ ត្រូវសម្អាត និងសម្លាប់មេរោគនៅកន្លែងធ្វើការរបស់ខ្លួនឲ្យបានត្រឹមត្រូវ បន្ទាប់ពីបម្រើសេវាកម្មអតិថិជនម្នាក់ៗរួច និងចន្លោះពេលត្រូវប្តូរអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក។

3.4.2. ធានាថា អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ទទួលបានសម្ភារផ្គត់ផ្គង់សម្អាត ដើម្បីពួកគេអាចសម្អាតផ្ទៃផ្សេងៗដោយផ្ទាល់នៅពេលចាំបាច់ នៅពេលគ្មានវត្តមានបុគ្គលិកសម្អាត។

3.4.3. សម្អាត និងសម្លាប់មេរោគលើផ្ទៃប៉ះពាល់ច្រើនគ្នានៅកន្លែងរួមឲ្យបានជាប្រចាំពេញមួយថ្ងៃ និងអនុលោមតាមផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់ ។ សម្អាត និងសម្លាប់មេរោគលើផ្ទៃ និងឧបករណ៍ប៉ះច្រើនគ្នាទាំងអស់ ដូចជា ដៃទ្វារ បង្កាន់ដៃ រ៉ូប៊ីណេទីក បង្គន់ ប៊ូតុងជណ្តើរយន្ត ប្រដាប់ផ្គត់ ឬញ្ជរខោអាវ គ្រឿងសង្ហារិម កុំព្យូទ័រ ទូរស័ព្ទ និងឧបករណ៍ផ្សេងទៀត ដែលមនុស្សប៉ះពាល់ពេញមួយថ្ងៃ។

3.4.4. បញ្ឈប់ការប្រើប្រាស់ឧបករណ៍ម្ហូបអាហារ និងភេសជ្ជៈរួមគ្នា នៅក្នុងបន្ទប់សម្រាក (រួមទាំង

ម៉ាស៊ីនឆុងកាហ្វេរួមគ្នាផងដែរ)។

3.4.5. ផ្គត់ផ្គង់ផលិតផលអនាម័យត្រឹមត្រូវនៅកន្លែងទទួលភ្ញៀវ និងកន្លែងធ្វើការទាំងអស់ ដែលរួមបញ្ចូលក្រដាសជូតដែលប្រើរួចចោល ដែលលាងដៃ និងក្រដាសជូតសម្លាប់មេរោគ។

3.4.6. សម្លាប់មេរោគនៅបញ្ជរបម្រើសេវា រទេះរុញ ប្រអប់ថត កញ្ចក់កាន់ដៃ ឧបករណ៍ និងផ្ទៃផ្សេងទៀត បន្ទាប់ពីបានប្រើដើម្បីបម្រើសេវាកម្មជូនអតិថិជនម្នាក់ៗរួច។

3.4.7. នៅពេលអាចធ្វើបាន កុំសម្អាតកំរាលឥដ្ឋ ដោយបោស ឬប្រើវិធីផ្សេងទៀត ដែលអាចឲ្យមេរោគខ្ចាត់ខ្ចាយលើខ្យល់។ ត្រូវប្រើម៉ាស៊ីនបូមធូលីមានតម្រង HEPA នៅពេលណាលអាចធ្វើបាន។

3.4.7.1. សក់អតិថិជនត្រូវបោះចោលដោយសុវត្ថិភាពនៅក្នុងធុងសម្រាម។

3.5. ពេលដែលអាចធ្វើទៅបាន ត្រូវហាមឃាត់អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក កុំឲ្យប្រើគ្រឿងបរិក្ខាររួមគ្នា ដូចជា ទូរស័ព្ទ ថេប្លេត ឬកុំព្យូទ័រ។ គ្រឿងសង្ហារិម ឧបករណ៍ ឬគ្រឿងបរិក្ខាណាដែលត្រូវប្រើដោយបុគ្គលលើសពីម្នាក់ ត្រូវសម្លាប់មេរោគ បន្ទាប់ពីបានប្រើរួចតាមរបៀបស្របតាមលក្ខខណ្ឌតម្រូវ ដែលចែងក្នុង[ផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់]។ ប្រសិនបើអ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក ត្រូវប្រើកន្លែងធ្វើការរួមគ្នា ដូចជា ការប្តូរវេន ដូច្នេះទីតាំងនោះត្រូវសម្លាប់មេរោគ តាមរបៀបស្របតាមលក្ខខណ្ឌតម្រូវ ដែលចែងក្នុង[ផែនការការពារជំងឺកូវីដ-19 សម្រាប់ទីតាំងជាក់លាក់] បន្ទាប់ពីការប្រើប្រាស់ម្តងៗ។

3.6. អនុវត្តវិធានការសុវត្ថិភាពសម្រាប់អតិថិជន ដែលរួមបញ្ចូល៖

3.6.1. សេវាកម្មដែលតម្រូវឱ្យអតិថិជនដោះម៉ាស់ ត្រូវបានហាមឃាត់ លើកលែងតែត្រូវបានលើកលែងដោយបទបញ្ញាស្តីពីម៉ាស់។

3.6.1.1. ការបក និងជ៉ាក់ចិញ្ចើម ការធ្វើរោមភ្នែក ការបករោមមុខ និងការធ្វើមុខផ្សេងទៀត ត្រូវបានហាមឃាត់ នៅពេលនេះ។

3.6.2. អតិថិជនត្រូវពាក់ម៉ាស់ មានខ្សែចងនឹងត្រចៀក ដើម្បីកុំឲ្យជ្រៀតជ្រែកនឹងការបម្រើសេវាកម្ម។

3.6.3. ផ្តល់អាវក្រៅ ឬក្រណាត់គ្របស្អាតឲ្យអតិថិជនម្នាក់ៗ។

3.6.4. ស្នើអតិថិជនមកតាមការណាត់ បន្ទាប់ពីបានកក់សម្អាតសក់ថ្មីៗ ដើម្បីកាត់បន្ថយពេលណាត់ ប្រសិនបើសមរម្យចំពោះការបម្រើសេវាកម្ម។

3.6.5. ពិចារណាលុបបំបាត់ជាបណ្តោះអាសន្ននូវសេវាកម្មផ្សេងៗដែលតម្រូវឲ្យផ្ទុំខ្យល់សម្ងួតរយៈពេលវែង។

3.6.6. ហាមឃាត់អតិថិជន មិនឱ្យនាំមនុស្សមកបន្ថែម នៅពេលណាត់ លើកលែងតែករណីលើកលែងដូចខាងក្រោម៖ (1) ប្រសិនបើអតិថិជនដែលទទួលសេវាកម្ម គឺជាអនីតិជន ពួកគេអាចនាំអាណាព្យាបាលជាមនុស្សពេញវ័យ (2) ប្រសិនបើអតិថិជន ដែលទទួលសេវាកម្ម គឺជាជនពិការ ពួកគេអាចនាំអ្នកផ្តល់សេវាថែទាំជាមនុស្សពេញវ័យ និង (3) អតិថិជនពេញវ័យអាចនាំកូនតូចៗរបស់ខ្លួន ប្រសិនបើពួកគេគ្មានជម្រើសថែទាំកុមារផ្សេងទៀតទេ។ អ្នកណាដែលចូលក្នុងគ្រឹះស្ថាន ត្រូវពិនិត្យរករោគសញ្ញាជំងឺកូវីដ-19 និងត្រូវរាប់បញ្ចូល នៅពេលគេសម្រេចថាតើ ទីតាំងមានចំនួនមនុស្សដល់កម្រិតរបស់ទីតាំង ឬយ៉ាងណា។

3.6.7. ហាមឃាត់អតិថិជន កុំឲ្យប្រមូលផ្តុំគ្នានៅកន្លែងទទួលភ្ញៀវ ឬកន្លែងផ្សេងទៀតក្នុងគ្រឹះស្ថាន។ ស្នើអតិថិជនរង់ចាំខាងក្រៅ ដោយពាក់ម៉ាស ឬក្នុងរថយន្តរបស់ខ្លួន មុនពេលណាត់ ។ នៅទីតាំងកាន់តែធ កន្លែងទទួលភ្ញៀវគួរមានអតិថិជនម្តងម្នាក់ ឬកែប្រែកន្លែងទទួលភ្ញៀវ ដើម្បីអាចរក្សាគម្លាតរូបកាយយ៉ាងតិចប្រាំមួយហ្វីត ដែលរួមបញ្ចូល ការយកកៅអី ឬ សាឡងចេញ ឬការដាក់របាំងលើកៅអី ឬសាឡង។

3.6.8. អ្នកផ្តល់សេវាកម្មអ៊ុតសក់ កាត់សក់ និងក្រចក មិនត្រូវបម្រើសេវាអតិថិជនច្រើននាក់ ក្នុងពេលតែមួយទេ (ឧទាហរណ៍ ខណៈពេលសក់អតិថិជនម្នាក់កំពុងស្ងួត អតិថិជនម្នាក់ទៀត ទទួលសេវាកម្មកាត់សក់)។ សេវាកម្មសម្រាប់អតិថិជនម្នាក់ ត្រូវតែបញ្ចប់ឲ្យរួចរាល់ មុនពេលអ្នកផ្តល់សេវាកម្មអ៊ុតសក់ និងកាត់សក់បម្រើសេវាកម្មជូនអតិថិជនថ្មី។

3.6.9. យកផលិតផលគំរូចេញ និងហាមឃាត់ការប្រើផលិតផលគំរូ។

3.6.10. កុំផ្តល់អាហារ និងភេសជ្ជៈជូនអតិថិជន។

3.6.11. យករបស់របរចល័តចេញពីផ្ទៃដែលមិនអាចសម្អាតបានសមរម្យ ដូចជា ខ្នើយទ្រាប់ ភួយ ឬ ទស្សនាវដ្តី។ ពិចារណាគ្រប ឬយកចេញនូវវត្ថុផ្សេងទៀតដែលពិបាកសម្អាត ដែល អតិថិជនប៉ះពាល់។

3.6.12. រៀបចំកៅអីរឹងមិនជ្រាប ឬកន្ត្រក ឬថង់ប្លាស្ទិក ឬថង់ក្រដាសធំៗ ឬផ្ទើរញ្ជូរអាវធំ/មួកសម្រាប់អតិថិជនដាក់សម្លៀកបំពាក់ និងរបស់របរផ្សេងទៀត។ សម្លាប់ មេរោគលើកៅអី កន្ត្រកប្លាស្ទិក និងផ្ទើរញ្ជូរអាវធំ/មួក បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។ ពេលញ្ជូររបស់របរ ត្រូវធានាថា របស់នោះមិនប៉ះពាល់នឹងរបស់របររបស់ អតិថិជនផ្សេងទៀតឡើយ។